ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧១
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០
**សាលដីកា**
លេខ ១៩៨ "V"
ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ប្រធាន
២.ឯកឧត្តម [redacted] ចៅក្រម
៣.ឯកឧត្តម [redacted] ចៅក្រមរបាយការណ៍
៤.ឯកឧត្តម [redacted] ចៅក្រម
៥.ឯកឧត្តម [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១០៧ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ចន្ថា និងបណ្តឹងសាទុក្ខលេខ១០៩ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាសភាស៊ើបសួរលេខ ១៣ ក្រ II ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**ជនត្រូវចោទ (ចុងបណ្តឹងសាទុក្ខ)**

១-ឈ្មោះ[redacted]អង្គារ៉ា ហៅ ពៅ ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ និងទីលំនៅបច្ចុប្បន្ន[redacted]ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]ស" ប្រពន្ធឈ្មោះ [redacted] កូនចំនួន ០៥ នាក់ ទោសពីមុនគ្មាន។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

២-ឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ ៤២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតនៅខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្នផ្ទ[redacted]ណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] ប្ដីឈ្មោះ [redacted] មានកូនចំនួន ០៦នាក់។ ទោសពីមុនគ្មាន។

**ដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ:** ផិត និងបទ អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ឯកពន្ធភាព និងមាត្រា៤៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

មានលោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិ

**ដើមបណ្ដឹងរដ្ឋប្បវេណី**

-ឈ្មោះ [redacted] ចន្ថា ហៅ ពៅ ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៤AEo ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ ៖**

កាលពីឆ្នាំ២០១០ ឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ៤១ឆ្នាំ និងកូនស្រីឈ្មោះ [redacted] កុសិតា អាយុ១៥ឆ្នាំ បានធ្វើដំណើរទៅលេងប្រទេសវៀតណាម ជាមួយឈ្មោះ [redacted] អង្គារ៉ា ភេទប្រុស អាយុ៤១ឆ្នាំ ។ ពេលទៅដល់ប្រទេសវៀតណាមឈ្មោះ [redacted] សេងហ៊ួយ និងកូនស្រីរួមជាមួយឈ្មោះ [redacted] អង្គារ៉ា និងអ្នករួមដំណើរផ្សេងទៀត បានស្នាក់នៅក្នុងសណ្ឋាគារ ដោយដេកមួយបន្ទប់រួមគ្នា។ ពេលកំពុងដេកក្នុងបន្ទប់ឈ្មោះ [redacted] អង្គារ៉ា [redacted] ជនរងគ្រោះឈ្មោ[redacted] កុសិតា ដែលដេកក្បែរជាមួយគ្នា ហើយបន្ទាប់មកឈ្មោះ [redacted] សេងហ៊ួយ ជាម្ដាយបាន[redacted]មួយឈ្មោ[redacted]អង្គារ៉ា នៅចំពោះមុខជនរងគ្រោះ។

នៅក្នុងឆ្នាំ២០១០ ដដែលនោះដែរឈ្មោះ [redacted] អង្គារ៉ា បានទៅលេងខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ជាមួយឈ្មោះ [redacted] សេងហ៊ួយ និងកូនស្រីឈ្មោះ [redacted] កុសិតា ទៀត ហើយពេលនៅខេត្តមណ្ឌលគិរី អ្នកទាំងបីបានដេកបន្ទប់ជាមួយគ្នា ខណៈពេលនោះឈ្មោះ [redacted] សេងហ៊ួយ បាន[redacted]មួយឈ្មោះ [redacted] អង្គារ៉ា នៅចំពោះមុខកូនតែម្ដង លុះដល់ព្រឹកឡើងពេលនាំគ្នាទៅលេងជ្រោះប៊ូស្រា ឈ្មោ[redacted] អង្គារ៉ា បានយកម្រាម[redacted] ភេទជនរងគ្រោះទៀត។

-បានឃើញ ដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ ៖

-លើកលែងចោទប្រកាន់លើ

-ឈ្មោះ[redacted]សេងហ៊ួយ ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ ពីបទ: ផិត និងបទ អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៧ នៃច្បាប់ស្ដីពីឯកពន្ធភាព និងមាត្រា ៤៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

-ឈ្មោ[redacted]អង្គារ៉ា ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង ពីបទៈ អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៥១ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ដែលប្តឹងមិនសុខចិត្តនឹងដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៥២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ដែលប្តឹងមិនសុខចិត្តនឹងដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៣ ក្រ II ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៥១ និងលេខ ៥៥២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]ន្ថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនត្រូវចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១០៧ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាសភាស៊ើបសួរលេខ ១៣ ក្រ II ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១០៨ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាសភាស៊ើបសួរលេខ ១៣ ក្រ II ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា៖ តាមការពិនិត្យទៅលើអង្គហេតុ និងការប្តឹងសាទុក្ខរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ហើយ តំណាងមហាអយ្យការពុំមានយោបល់អ្វីបន្ថែមទៅលើសារណារបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញទេ។



Scanned with CamScanner

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

សូមក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

+លោក[redacted]រ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទទាំងពីរបានធ្វើសេចក្តីសន្និដ្ឋានថា៖ អង្គហេតុក្នុងរឿងនេះគឺមានចំនួន០២កន្លែង គឺអង្គហេតុកើតនៅប្រទេសវៀតណាម និងអង្គហេតុកើតនៅខេត្តមណ្ឌលគិរី គឺអង្គហេតុនេះបាននាំឱ្យមានការចោទប្រកាន់ ក្នុងបទល្មើសចំនួនពីរ ទី១ គឺបទ ផិត តាមមាត្រា៧ នៃច្បាប់ឯកពន្ធភាព និងទី២ មាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ខ្លួនសូមចាប់ផ្តើមពីពាក្យចោទប្រកាន់ បើតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការចោទប្រកាន់លុះត្រាតែមានភស្តុតាងគ្រប់គ្រាន់ ជាក់ស្តែងតាមឯកសារភស្តុតាង និងសាលដីកាសាលាឧទ្ធរណ៍ គឺក្នុងនាមខ្លួនជាមេធាវីសូមសន្និដ្ឋានថា រឿងនេះគ្មានភស្តុតាងគ្រប់គ្រាន់ ដោយសារតែការចោទប្រកាន់ គឺយោងទៅលើតែចម្លើយរបស់ជនរងគ្រោះដែលមាន២នាក់ ជាបងប្អូននិងគ្នា ហើយជនរងគ្រោះជាក្មេងការចងចាំក៏មិនគ្រប់គ្រាន់ និងបាននិយាយថា ពុករបស់គាត់ជាអ្នកបង្គាប់ឱ្យនិយាយ ដូចនេះការមន្ទិលសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ ដូចនេះផ្អែកទៅលើភស្តុតាងមិនគ្រប់គ្រាន់ និងការដកពាក្យបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការសម្រេចលើកលែងចោទប្រកាន់របស់តុលាការថ្នាក់ក្រោម សូមតុលាការពិចារណា និងឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

សំណូមពរ គាំទ្រនូវដីកាលើកលែងចោទរបស់សាលាដំបូង និងសូមលើកលែងចោទប្រកាន់កូនខ្លួន។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០៧ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ចន្ថា និងបណ្តឹងសាទុក្ខលេខ១០៩ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ចន្ថា បានប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ ១៣ ក្រ II ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ប៉ុន្តែនៅក្នុងអំឡុងពេលនៃចំណាត់ការសំណុំរឿងនៅតុលាការកំពូលឈ្មោះ[redacted]ចន្ថា បានដាក់ពាក្យសុំដកបណ្តឹងសាទុក្ខចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ ដែលខ្លួនបានប្តឹងនេះវិញ នោះតុលាការកំពូលនឹងធ្វើកំណត់ហេតុ ស្តីពីការសុំដកពាក្យបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមមាត្រា៤៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-យល់ឃើញថា តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ បានប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ១៣ ក្រII ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ និងសុំឱ្យតុលាការកំពូលបង្វិល



Scanned with CamScanner

សំណុំរឿងព្រហ្មទណ្ឌនេះមកសាលាឧទ្ធរណ៍ សភាស៊ើបសួរផ្សេងជំនុំជម្រះជាថ្មីឡើងវិញ។ ចំពោះករណីនេះតុលាការកំពូលពិនិត្យឃើញថា បណ្តឹងសាទុក្ខខាងលើរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ដោយភ្ជាប់មកជាមួយនូវសារណាលេខ៣៥៩ មហក/១២ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ ពុំបានលើកឡើងអំពីអង្គហេតុ អង្គច្បាប់ និងមូលហេតុឱ្យបានច្បាស់លាស់ដូចមានចែងក្នុងចំណុចណាមួយនៃមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។ ដូច្នេះតុលាការកំពូលពុំអាចពិចារណាលើបណ្តឹងសាទុក្ខនេះបានទេ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៣ ក្រII ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. បដិសេធបណ្តឹងសាទុក្ខលេខ ១០៩ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៣ ក្រ II ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| ឯកឧត្តម | [redacted] | ចៅក្រម |
| ឯកឧត្តម | [redacted] | ចៅក្រម |
| ឯកឧត្តម | [redacted] | ចៅក្រម |
| ឯកឧត្តម | [redacted] | ចៅក្រម |
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃពុធ ១៣រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
ក្រឡាបញ្ជី
[redacted]

**បានឃើញ**
ថ្ងៃពុធ ១៣រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
ប្រធានអង្គជំនុំជម្រះ
[redacted]



Scanned with CamScanner